ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាព
# សម្រាប់អនុវត្តយុទ្ធសាស្ត្រ
# ស្តីពី
# ការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
# ឆ្នាំ ២០២៥ - ២០២៨




រៀបចំដោយ៖
លេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
២០២៥

# ផែនការសកម្មភាព
# សម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពី
# ការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
# ឆ្នាំ ២០២៥-២០២៨


លេខាធិការដ្ឋាន

ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

ឆ្នាំ ២០២៥

# អារម្ភកថា

ក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយនេះ, បច្ចេកវិទ្យាឌីជីថល បានក្លាយជាផ្នែកមួយដ៏សំខាន់នៃការរស់នៅ, ការរៀនសូត្រ, ការប្រកបអាជីវកម្ម និង ការផ្តល់សេវាសាធារណៈ ជូនធុរជន និង សាធារណជនទូទៅ។ នៅក្នុងវិស័យសាធារណៈ, បច្ចេកវិទ្យាឌីជីថល ដើរតួនាទីជាគន្លឹះដ៏សំខាន់ ក្នុងការជំរុញការកែទម្រង់នានានៅកម្ពុជា ជាពិសេសការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃការិយាធិបតេយ្យ, បង្កើនប្រសិទ្ធភាពនៃរដ្ឋបាលសាធារណៈ, ពង្រឹងអនុលោមភាព និង កែលម្អបរិយាកាសធុរកិច្ចនៅកម្ពុជា។ ការធ្វើទំនើបកម្មការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់មួយរបស់រាជរដ្ឋាភិបាល ដែលត្រូវបានអនុវត្តជាប្រចាំ ចាប់ពីនីតិកាលទី ៦ នៃរដ្ឋសភា រហូតដល់បច្ចុប្បន្ន និង តទៅអនាគត។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានរៀបចំ និង ដាក់ឱ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន តាំងពីឆ្នាំ ២០២០ ដែលបានអនុញ្ញាតឱ្យធុរជនអាចចុះបញ្ជីអាជីវកម្មជាកញ្ចប់ក្នុងជំហានដំបូងនៃវដ្តធុរកិច្ច។ ទោះយ៉ាងនេះក្តី, វឌ្ឍនភាពនៃការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច នៅមានកម្រិតនៅឡើយ ដែលទាមទារឱ្យមានការគិតគូរ និង រៀបចំជាយុទ្ធសាស្ត្រក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលតែម្តង។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលបានដាក់ចេញ «**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨**» កាលពីខែ កុម្ភៈ ឆ្នាំ ២០២៥ កន្លងទៅ ដោយបានកំណត់ចក្ខុវិស័យច្បាស់លាស់ក្នុងការ«**ចូលរួមបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចដែលមានប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និង តម្លាភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង**» និង មានគោលបំណង «**បង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡានិង បំពេញឱ្យគ្នាទៅវិញទៅមក សំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និងលើកកម្ពស់ការបំពេញអនុលោមភាព**»។

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ និង គោលបំណងខាងលើនេះ, លេខាធិការដ្ឋានក្រុមការងាររៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច បានសហការជាក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ «**ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨**» អមជាមួយការរៀបចំបញ្ជីសេវាអាទិភាពខ្ពស់ពាក់ព័ន្ធធុរកិច្ច ដែលត្រូវធ្វើឌីជីថលូបនីយកម្មសម្រាប់រយៈពេល ៤ ឆ្នាំ ខាងមុខ សំដៅសម្រេចឱ្យបានយ៉ាងតិច ៨០% នៃសេវាអាទិភាពសរុប។ បន្ថែមពីនេះ, ផែនការសកម្មភាពនេះ បានកំណត់សកម្មភាពលម្អិត, តួនាទី និង ភារកិច្ចរបស់ក្រសួង ស្ថាប័នដែលត្រូវដឹកនាំ និងចូលរួមអនុវត្ត, របបនៃការរាយការណ៍ច្បាស់លាស់ និង សូចនាករសមិទ្ធកម្មគន្លឹះជាក់លាក់សម្រាប់ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តរបស់ក្រសួង ស្ថាប័ន។ ការដាក់ចេញផែនការសកម្មភាពនេះ ក្លាយជាមគ្គុទេសក៍ និង ជាមូលដ្ឋានសម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តសកម្មភាពស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពខ្ពស់។ ផែនការសកម្មភាពនេះ ត្រូវចាត់ទុកជា "ឯកសាររស់" ដែលជាកម្មវត្ថុនៃការពិចារណា និង កែសម្រួលបន្ថែមនាពេលអនាគតស្របតាមស្ថានភាពជាក់ស្តែងនៅកម្ពុជា, ឧត្តមានុវត្តន៍ និង និន្នាការនៃការអភិវឌ្ឍថ្មីលើការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ចទាំងក្នុងបរិការណ៍តំបន់ និង សកល។

ជាទីបញ្ចប់, ក្នុងនាមប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ខ្ញុំសូមថ្លែងអំណរគុណ និង វាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច**, អនុប្រធាន និង សមាជិក ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង លេខាធិការដ្ឋាន ដែលបានខិតខំប្រឹងប្រែងរៀបចំផែនការសកម្មភាពនេះឡើង។ ខ្ញុំសូមលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន ផ្តល់សេវា និង ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់បន្តចូលរួមផ្តល់កិច្ចសហការល្អ និង ចូលរួមអនុវត្តផែនការសកម្មភាព ប្រកបដោយស្មារតីទទួលខុសត្រូវ និង មានប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកបង្កើតបរិយាកាសអំណោយផល និង ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែ មិគសិរ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

**អារម្ភកថា** ........ I
**បញ្ជីអក្សរកាត់** ........ IV
**១. សេចក្តីផ្តើម** ........ ១
**២.គោលបំណង និង អភិក្រម** ........ ១
**៣. យន្តការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ** ........ ២
**៤. តួនាទី និង ភារកិច្ចរបស់ក្រសួង ស្ថាប័ន** ........ ៣
៤.១. ក្រសួង ស្ថាប័ន ដឹកនាំអនុវត្ត ........ ៣
៤.២. ក្រសួង ស្ថាប័ន ចូលរួមអនុវត្ត ........ ៣
៤.៣. លេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ........ ៣
៤.៤. អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ ........ ៤
**៥. សេចក្តីសន្និដ្ឋាន** ........ ៤
**ឧបសម្ព័ន្ធ ១ ៖ តារាងសកម្មភាព នៃការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ២០២៥-២០២៨** ........ ៥
**ឧបសម្ព័ន្ធ ២ ៖ តារាងសូចនាករសមិទ្ធកម្មគន្លឹះ** ........ ៧
**ឧបសម្ព័ន្ធ ៣ ៖ តារាងសេវាអាទិភាពរបស់ក្រសួង ស្ថាប័ន ដែលត្រូវរៀបចំជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច** ........ ៨

# បញ្ជីអក្សរកាត់

| | |
|---|---|
| ១. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ក.ប.ស.អ. |
| ២. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ក.អ.ក. |
| ៣. ក្រសួងអប់រំ យុវជន និង កីឡា | ក.អ.យ.ក. |
| ៤. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ក.ដ.ន.ស. |
| ៥. ក្រសួងមហាផ្ទៃ | ក.ម.ផ. |
| ៦. ក្រសួងយុត្តិធម៌ | ក.យ. |
| ៧. ធនាគារជាតិនៃកម្ពុជា | ធ.ក. |
| ៨. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ក.ក.ស.ក. |
| ៩. ក្រសួងពាណិជ្ជកម្ម | ក.ព.ណ. |
| ១០. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | ក.ឧ.វ.ប.ន. |
| ១១. ក្រសួងរ៉ែ និង ថាមពល | ក.រ.ថ. |
| ១២. ក្រសួងបរិស្ថាន | ក.ប.ស្ថ. |
| ១៣. ក្រសួងព័ត៌មាន | ក.ព.ម. |
| ១៤. ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | ក.ប.ទ. |
| ១៥. ក្រសួងសុខាភិបាល | ក.ស.ខ. |
| ១៦. ក្រសួងសាធារណការ និង ដឹកជញ្ជូន | ក.ស.ដ. |
| ១៧. ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ | ក.វ.វស. |
| ១៨. ក្រសួងទេសចរណ៍ | ក.ទ. |
| ១៩. ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | ក.ក.ប. |
| ២០. រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | រ.ល.អ.ស. |
| ២១. គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល | គ.រ.ឌ. |
| ២២. គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល | គ.ស.ធ.ឌ. |
| ២៣. គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | គ.ក.ស. |
| ២៤. អគ្គនាយកដ្ឋានពន្ធដារ | អ.ព.ដ. |
| ២៥. អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា | អ.គ.រ. |
| ២៦. គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា | គ.ល.ក. |
| ២៧. និយ័តករមូលបត្រកម្ពុជា | ន.ម.ក. |
| ២៨. និយ័តករបរធនបាលកិច្ច | ន.ប.ធ. |
| ២៩. និយ័តករគណនេយ្យ និង សវនកម្ម | ន.គ.ស. |
| ៣០. និយ័តករធានារ៉ាប់រងកម្ពុជា | ន.ធ.ក. |
| ៣១. និយ័តករអាជីវកម្មអចលនវត្ថុ និង បញ្ចាំ | ន.អ.ប. |

## ១. សេចក្តីផ្តើម

ក្នុងបរិការណ៍ដែលបច្ចេកវិទ្យា បាន និង កំពុងរីកចម្រើនយ៉ាងឆាប់រហ័ស និង ក្នុងគោលបំណងធ្វើទំនើបកម្មការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច, រាជរដ្ឋាភិបាល បានសម្រេចដាក់ចេញនូវ "**យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**" កាលពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២៥ កន្លងទៅ ដែលមាន**ចក្ខុវិស័យ** "ចូលរួមបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដែលមានប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, និង តម្លាភាព ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង" និង **គោលបំណង** "បង្កើតប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ប្រកបដោយភាពរស់រវើក, ភាពធន់, ប្រទាក់ក្រឡា និង បំពេញឱ្យគ្នាទៅវិញទៅមក សំដៅពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាសាធារណៈសម្រាប់ធុរកិច្ច និង លើកកម្ពស់ការបំពេញអនុលោមភាព"។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និង គោលបំណងខាងលើ, យុទ្ធសាស្ត្រនេះ បានកំណត់**គោលដៅ**សំខាន់ចំនួន ៤ រួមមាន៖ ១)- កែសម្រួល ឬ លុបចេញសេវា និង នីតិវិធីការងារក្នុងការស្នើសុំសេវា ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬ មិនមានតម្លៃបន្ថែមខ្ពស់ ដើម្បីបង្រួម និង ធានាភាពងាយស្រួល ក្នុងការស្នើសុំសេវាសម្រាប់ធុរកិច្ចដល់ធុរជន, ២)- កសាង និង អភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់សេវាអេឡិចត្រូនិក ឱ្យដំណើរការនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច ផ្អែកលើគោលការណ៍ប្រសិទ្ធភាពនៃការវិនិយោគ, ៣)- ធ្វើអាទិភាវូបនីយកម្មសេវាសម្រាប់ធុរកិច្ចផ្អែកលើភាពចាំបាច់ និង តម្រូវការខ្ពស់ និង ដាក់ឱ្យដំណើរការសេវាចំនួន ៨០% នៃសេវាអាទិភាពទាំងនោះតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានត្រឹមឆ្នាំ ២០២៨, និង ៤)- ផ្សព្វផ្សាយព័ត៌មាន និង បញ្ជ្រាបការយល់ដឹងអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីលើកកម្ពស់ការចូលរួមពីគ្រប់តួអង្គពាក់ព័ន្ធ។

ទន្ទឹមនេះ, យុទ្ធសាស្ត្រនេះ បានដាក់ចេញនូវ**អាទិភាពជាយុទ្ធសាស្ត្រ**ចំនួន ៥ មានដូចជា៖ ១)- ការពិនិត្យឡើងវិញ និង កែសម្រួលសេវានិងនីតិវិធីស្នើសុំ, ២)- ការអភិវឌ្ឍ និង ការបន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្តល់សេវាអេឡិចត្រូនិកគាំទ្រធុរកិច្ច, ៣)- ការរៀបចំ និង ការធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាពក្នុងក្របខ័ណ្ឌធុរកិច្ច, ៤)- ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ៥)- ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។ អាទិភាពជាយុទ្ធសាស្ត្រទាំង ៥ នេះ មានវិធានការគន្លឹះសរុបចំនួន ២១។

ដើម្បីធានាបានប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពខ្ពស់ក្នុងការអនុវត្ត, យុទ្ធសាស្ត្រខាងលើ បានចង្អុលបង្ហាញឱ្យគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំផែនការសកម្មភាពច្បាស់លាស់ ស្របតាមទម្រង់ដែលរៀបចំដោយលេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច (ហៅកាត់ថា លេខាធិការដ្ឋាន) និង រាយការណ៍វឌ្ឍនភាពនៃការអនុវត្តជាប្រចាំមកលេខាធិការដ្ឋានផងដែរ។

## ២- គោលបំណង និង អភិក្រម

"**ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨**" មានគោលបំណងចម្បងកំណត់នូវសកម្មភាពគោលសំខាន់ៗ និង សូចនាករជាក់លាក់ ដើម្បីជាមូលដ្ឋានសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ ក្នុងរយៈពេល ៤ ឆ្នាំ ពីឆ្នាំ ២០២៥ ដល់ឆ្នាំ ២០២៨, ព្រមទាំងសម្រាប់ការងារតាមដាន និង ត្រួតពិនិត្យវឌ្ឍនភាពជាប្រចាំ និង ការវាយតម្លៃលទ្ធផលផងដែរ។

ដើម្បីបង្កភាពងាយស្រួលដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងការអនុវត្ត និង ការរាយការណ៍វឌ្ឍនភាព, ការរៀបចំផែនការសកម្មភាពនេះ ផ្ដោតលើ **សកម្មភាពសំខាន់ៗ** ត្រឹមកម្រិតអាទិភាពជាយុទ្ធសាស្ត្រប៉ុណ្ណោះ ជាជាងលម្អិតតាមវិធានការគន្លឹះនីមួយៗ សំដៅសម្រេចបាន **សូចនាករសមិទ្ធកម្មគន្លឹះ** ដែលផ្ដោតលើការរៀបចំសេវាសម្រាប់ធុរកិច្ច ជាសេវាអេឡិចត្រូនិក នៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច។

ជាអភិក្រម, ផែនការសកម្មភាពនេះ ត្រូវបានរៀបចំដោយប្រើប្រាស់អភិក្រមចម្រុះ គឺ ១)- **អភិក្រមពីលើចុះក្រោម** (Top-Down Approach) ដោយលេខាធិការដ្ឋាន បានរៀបចំទម្រង់ផែនការសកម្មភាព ដែលរំលេចពីសកម្មភាព និង ចំណុចដៅជារួមសម្រាប់រយៈពេល ៤ ឆ្នាំ ដូចមានលម្អិតក្នុងឧបសម្ព័ន្ធ ១, និង ២)- **អភិក្រមពីក្រោមឡើងលើ** (Bottom-Up Approach) ដោយក្រសួង ស្ថាប័ន ត្រូវពិនិត្យ និង ផ្ដល់ធាតុចូលលើផែនការសកម្មភាពនេះ ព្រមទាំងធ្វើអាទិភាវូបនីយកម្មសេវាសម្រាប់ធុរកិច្ច ដែលត្រូវរៀបចំជាសេវាអេឡិចត្រូនិកឱ្យបានជាក់លាក់ទៅតាមឆ្នាំនីមួយៗ ផ្អែកតាមបញ្ជីសេវាអាទិភាពដែលស្នើដោយលេខាធិការដ្ឋាន។ បញ្ជីសេវាអាទិភាពរបស់ក្រសួង ស្ថាប័នផ្ដល់សេវា នឹងត្រូវបូកសរុប និង ដាក់បញ្ចូលទៅក្នុង ឧបសម្ព័ន្ធ ៣ នៃផែនការសកម្មភាពនេះ ដើម្បីផ្ដល់មូលដ្ឋានរឹងមាំសម្រាប់ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃជារួម។

## ៣. ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

ដើម្បីធានាបាននូវការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ នៃការអនុវត្តផែនការសកម្មភាព ប្រកបដោយប្រសិទ្ធភាពខ្ពស់, ការរៀបចំរបាយការណ៍ ត្រូវបានបែងចែកទៅតាមប្រភេទ និង វដ្តនៃការរាយការណ៍ ដូចខាងក្រោម៖

**ក. របាយការណ៍តាមដានវឌ្ឍនភាព៖** សំដៅដល់របាយការណ៍តាមដាន និង ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តសកម្មភាពរបស់ក្រសួង ស្ថាប័ន ដែលត្រូវរៀបចំជាប្រចាំឆមាស និង ប្រចាំឆ្នាំ ឬ តាមការស្នើសុំបន្ថែមរបស់លេខាធិការដ្ឋាន។ ក្រសួង ស្ថាប័ន ត្រូវរៀបរាប់អំពីវឌ្ឍនភាពការងារ ស្របតាមផែនការសកម្មភាព ដូចមានក្នុងឧបសម្ព័ន្ធ ១, បញ្ហាប្រឈម ដំណោះស្រាយ ព្រមទាំងសំណូមពរនានាផងដែរ។ ដោយឡែក, លេខាធិការដ្ឋាន ត្រូវធ្វើការបូកសរុប និង រាយការណ៍វឌ្ឍនភាពជារួមជូន ក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

**ខ. របាយការណ៍វាយតម្លៃ៖** សំដៅដល់របាយការណ៍វាយតម្លៃនៅចុងអាណត្តិ ដែលត្រូវធ្វើឡើងនៅចុងឆ្នាំ ២០២៨ ឬ យ៉ាងយូរដើមឆ្នាំ ២០២៩ ដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល (គ.ស.ធ.ឌ.)។ ការវាយតម្លៃនេះនឹងផ្ដោតលើសូចនាករសមិទ្ធកម្មគន្លឹះចំនួន ២ រួមមាន៖ ១)- ភាគរយនៃសេវាសម្រាប់ធុរកិច្ចដែលមានអាទិភាពខ្ពស់ ត្រូវបានរៀបចំជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច, និង ២)- ភាគរយនៃក្រសួង ស្ថាប័នដែលមានសេវាសម្រាប់ធុរកិច្ច បានចូលក្នុងប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ច (ដូចមានលម្អិតក្នុងឧបសម្ព័ន្ធ ២) ដែលអាចចាត់ទុកជាកត្តាកំណត់ភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រជារួម។

ជាមួយគ្នានេះ, ការតាមដាន ត្រួតពិនិត្យ និង ការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ត្រូវបែងចែកលទ្ធផលទៅតាមកម្រិតវឌ្ឍនភាពនីមួយៗ ដូចខាងក្រោម៖

- ពណ៌បៃតងចាស់ ● សម្រាប់វឌ្ឍនភាពសម្រេចបានពេញលេញ
- ពណ៌បៃតងខ្ចី ● សម្រាប់វឌ្ឍនភាពសម្រេចបានជិតពេញលេញ
- ពណ៌លឿង ● សម្រាប់វឌ្ឍនភាពសម្រេចបានវង្វង់ពាក់កណ្ដាល
- ពណ៌ក្រហម ● សម្រាប់សកម្មភាព ដែលមិនមានវឌ្ឍនភាព ឬ មិនបានអនុវត្ត។

## ៤. តួនាទី និង ភារកិច្ចរបស់ក្រសួង ស្ថាប័ន

ដើម្បីឱ្យការអនុវត្តផែនការសកម្មភាពនេះ ប្រព្រឹត្តទៅបានដោយរលូន និង សម្រេចបានលទ្ធផលតាមការគ្រោងទុក, ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមអនុវត្តតួនាទី និង ភារកិច្ចដូចខាងក្រោម៖

### ៤.១. ក្រសួង ស្ថាប័ន ដឹកនាំអនុវត្ត

ក្រសួង ស្ថាប័ន ដឹកនាំការអនុវត្តមានតួនាទី និង ភារកិច្ចដូចតទៅ៖

- រៀបចំផែនការសកម្មភាព ចំណុចដៅ និង មធ្យោបាយផ្ទៀងផ្ទាត់ ដែលគាំទ្រដល់ការអនុវត្តអាទិភាពជាយុទ្ធសាស្ត្រ
- ដឹកនាំ និង សម្របសម្រួលជាមួយក្រសួង ស្ថាប័នចូលរួមអនុវត្ត ដើម្បីពិនិត្យ និង តាមដានវឌ្ឍនភាពនៃការអនុវត្តសកម្មភាពនីមួយៗ
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពស្របតាមវដ្តរាយការណ៍
- ត្រូវមានការទទួលខុសត្រូវលើភាពត្រឹមត្រូវ ពេញលេញ និង គុណភាពនៃព័ត៌មាន និង ទិន្នន័យដែលបានរាយការណ៍។

### ៤.២. ក្រសួង ស្ថាប័នចូលរួមអនុវត្ត

ក្រសួង ស្ថាប័ន ចូលរួមអនុវត្តមានតួនាទី និង ភារកិច្ចដូចតទៅ៖

- ចូលរួមសហការជាមួយក្រសួង ស្ថាប័នដឹកនាំអនុវត្ត ដើម្បីរៀបចំផែនការសកម្មភាព និង របាយការណ៍វឌ្ឍនភាព
- ចូលរួមត្រួតពិនិត្យ និង ផ្តល់យោបល់លើការអនុវត្តផែនការសកម្មភាព
- ចូលរួមសហការអនុវត្តសកម្មភាពប្រកបដោយភាពបុរេសកម្ម ដើម្បីធានាបាននូវប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាព
- សហការប្រមូល និង ផ្តល់ទិន្នន័យពាក់ព័ន្ធផ្សេងៗតាមការចាំបាច់ប្រកបដោយគុណភាព និង ទាន់ពេលវេលា
- ចូលរួមអនុវត្តវិធានការនានា ពាក់ព័ន្ធការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

### ៤.៣. លេខាធិការដ្ឋានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

លេខាធិការដ្ឋាន មានតួនាទី និង ភារកិច្ចដូចតទៅ៖

- រៀបចំទម្រង់សេចក្តីព្រាងសកម្មភាព ដែលគាំទ្រដល់ការអនុវត្តអាទិភាពជាយុទ្ធសាស្ត្រទាំង ៥
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នទទួលបន្ទុក លើការដឹកនាំ និង ចូលរួមអនុវត្ត ដើម្បីរៀបចំផែនការសកម្មភាព និង របាយការណ៍វឌ្ឍនភាព ព្រមទាំងធានានូវការផ្តល់ និង ទទួលទិន្នន័យប្រកបដោយប្រសិទ្ធភាពខ្ពស់
- បូកសរុបរបាយការណ៍តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពប្រចាំឆមាស និង ប្រចាំឆ្នាំជូនក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច
- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង វិភាគទិន្នន័យ ដែលទទួលបានពីក្រសួង ស្ថាប័ន។

### ៤.៤. អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ.

អគ្គលេខាធិការដ្ឋាន គ.ស.ធ.ឌ. មានតួនាទី និង ភារកិច្ចដូចតទៅ៖

- រៀបចំសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់ការវាយតម្លៃ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នលើការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន ក្នុងការប្រមូលទិន្នន័យ និង របាយការណ៍ ព្រមទាំងធានានូវការគ្រប់គ្រងទិន្នន័យប្រកបដោយប្រសិទ្ធភាពខ្ពស់
- រៀបចំរបាយការណ៍វាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ជូនប្រមុខរាជរដ្ឋាភិបាល
- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និង វិភាគទិន្នន័យ ដែលទទួលបានពីក្រសួង ស្ថាប័ន។

## ៥. សេចក្តីសន្និដ្ឋាន

**ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨** គឺជាបណ្តុំនៃផែនការសកម្មភាពរៀបចំឡើង ដើម្បីគាំទ្រ និង ជំរុញដល់ការអនុវត្ត **យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨** សំដៅឈានទៅបង្កើតបាន **"ប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច"** មួយដ៏រឹងមាំ, បំពេញគ្នាទៅវិញទៅមក និង រស់រវើក ដែលគាំទ្រដល់ការបង្កើតបរិយាកាសអំណោយផលសម្រាប់ការធ្វើធុរកិច្ច តាមរយៈការផ្តល់សេវាអេឡិចត្រូនិក។

ដើម្បីសម្រួល និង កាត់បន្ថយបន្ទុករបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការរាយការណ៍, ផែនការសកម្មភាពនេះ បានកំណត់សកម្មភាពគោលសំខាន់ៗ និង សូចនាករពាក់ព័ន្ធ ត្រឹមកម្រិតអាទិភាពជាយុទ្ធសាស្ត្រប៉ុណ្ណោះ ដោយមិនលម្អិតដល់កម្រិតវិធានការគន្លឹះឡើយ។ បន្ថែមលើនេះ, ការវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រជារួម ក៏នឹងពិនិត្យលើ**សូចនាករសមិទ្ធកម្មគន្លឹះ** ២ ប៉ុណ្ណោះ និង ផ្តោតលើការរៀបចំសេវាសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន ជាសេវាអេឡិចត្រូនិកពេញលេញ ក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ច។

ផែនការសកម្មភាពនេះ ត្រូវបានចាត់ទុកជា **"ឯកសាររស់"** ដែលអាចនឹងធ្វើបច្ចុប្បន្នកម្ម ក្នុងករណីចាំបាច់ ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍ និង តម្រូវការជាក់ស្តែងនៃការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។

## ឧបសម្ព័ន្ធ ១ ៖ តារាងសកម្មភាពនៃការអនុវត្តយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨

| ល.រ | សកម្មភាព | ឯកតា | ចំណុចដៅ | | | | មធ្យោបាយផ្ទៀងផ្ទាត់ | ក្រសួង ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|
| | | | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | | |
| អាទិភាពជាយុទ្ធសាស្ត្រទី១៖ ការពិនិត្យឡើងវិញ និង កែសម្រួលសេវា និង នីតិវិធីស្នើសុំ | | | | | | | | |
| ១.១ | ពិនិត្យឡើងវិញ និង រៀបចំកែសម្រួលនីតិវិធីស្នើសុំ លើសេវាសម្រាប់ធុរកិច្ចអាទិភាព ដែលនឹងត្រូវរៀបចំជាសេវាអេឡិចត្រូនិក[1] | សេវា | យ៉ាងតិច ៩២ | យ៉ាងតិច ១៣៧ | យ៉ាងតិច ២២៩ | យ៉ាងតិច ២៣៨ | បញ្ជីសេវាដែលបានកែសម្រួលនីតិវិធី | -គ.ស.ធ.ឧ. (ដឹកនាំ)<br>-ក្រសួង ស្ថាប័នផ្ដល់សេវា |
| អាទិភាពជាយុទ្ធសាស្ត្រទី២៖ ការអភិវឌ្ឍ និង បន្តធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ផ្ដល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | | | | | | | | |
| ២.១ | រៀបចំសេវាសម្រាប់ធុរកិច្ចរបស់ក្រសួង ស្ថាប័ន ជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច[2] | សេវា | បន្ថែមថ្មី ៩២ | បន្ថែមថ្មី ១៣៧ | បន្ថែមថ្មី ២២៩ | បន្ថែមថ្មី ២៣៨ | បញ្ជីសេវាដែលបានអភិវឌ្ឍជាសេវាអេឡិច-ត្រូនិកសម្រាប់ធុរកិច្ច | ក្រសួង ស្ថាប័នផ្ដល់សេវា |
| អាទិភាពជាយុទ្ធសាស្ត្រទី៣៖ ការរៀបចំ និង ធ្វើទំនើបកម្មទិន្នន័យគោលឱ្យមានគុណភាព ក្នុងក្របខ័ណ្ឌធុរកិច្ច | | | | | | | | |
| ៣.១ | បើកចំហរទិន្នន័យគោលរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីឌីជីថលសម្រាប់ធុរកិច្ចតាមរយៈថ្នាល CamDX | ក្រសួង ស្ថាប័ន | បន្ថែមថ្មី ២ | បន្ថែមថ្មី ២ | បន្ថែមថ្មី ២ | បន្ថែមថ្មី ២ | បញ្ជីក្រសួង ស្ថាប័នដែលបានបើកចំហរទិន្នន័យគោល | -លេខាធិការដ្ឋាន (ដឹកនាំ)<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| អាទិភាពជាយុទ្ធសាស្ត្រទី៤៖ ការជំរុញការផ្សព្វផ្សាយព័ត៌មានអំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | | | | | | | | |
| ៤.១ | រៀបចំផ្សព្វផ្សាយសៀវភៅមគ្គុទេសក៍, វីដេអូ និង ផ្ទាំងផ្សព្វផ្សាយ (Poster) អំពីសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចតាមប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ | ឯកសារ/ វីដេអូ/ ផ្ទាំងផ្សព្វផ្សាយ | ២ | ២ | ២ | ២ | របាយការណ៍ | -ក្រសួង ស្ថាប័នផ្ដល់សេវា (ដឹកនាំ)<br>-លេខាធិការដ្ឋាន |

[1] ការពិនិត្យឡើងវិញ និង កែសម្រួលនីតិវិធីសេវានេះ សំដៅដល់ការកាត់បន្ថយព័ត៌មាននៃពាក្យស្នើសុំ និង ការកាត់បន្ថយឯកសារភ្ជាប់ក្នុងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬ វិញ្ញាបនបត្រ ជាដើម។ ក្នុងន័យនេះ, រាល់សេវាពាក់ព័ន្ធធុរកិច្ចទាំងឡាយណា ដែលត្រូវបានកាត់បន្ថយព័ត៌មាន ឬ ឯកសារភ្ជាប់ នឹងត្រូវរាប់ជាការកែសម្រួលនីតិវិធីស្នើសុំ។

[2] ឆ្នាំ ២០២៤ គឺជា ឆ្នាំមូលដ្ឋាន (Baseline) ដែលមានសេវាចំនួន ៣៧ សេវា។ គិតត្រឹមថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០២៥, សេវាពាក់ព័ន្ធធុរកិច្ចចំនួន ៥៥ ត្រូវបានចាត់ទុកជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។ ក្នុងន័យនេះ, លេខាធិការដ្ឋាន ត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដើម្បីអភិវឌ្ឍសេវាបន្ថែមចំនួន ៧៤ ជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ចសម្រាប់ឆ្នាំ ២០២៥។

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤.២ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយហេដ្ឋារចនាសម្ព័ន្ធសាធារណៈឌីជីថល | លើក | - | ១ | ១ | ១ | របាយការណ៍ | -លេខាធិការដ្ឋាន (ដឹកនាំ)<br>-គ.រ.ឌ. |
| ៤.៣ | រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និង/ឬ ពិព័រណ៍អំពីអត្ថប្រយោជន៍ និង នីតិវិធីស្នើសុំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | លើក | - | ១ | ១ | ១ | របាយការណ៍ | ក្រសួង ស្ថាប័នផ្តល់សេវា |
| អាទិភាពជាយុទ្ធសាស្ត្រទី៥ ៖ ការលើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវា និង ការរៀបចំយន្តការគាំទ្រអ្នកប្រើប្រាស់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | | | | | | | | |
| ៥.១ | រៀបចំផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីប្រតិបត្តិទទួលបន្ទុកផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច និង ផ្តល់កិច្ចគាំទ្រអ្នកស្នើសុំសេវា | ផែនការ | | រៀបចំ និង បញ្ចប់ | - | - | ឯកសារផែនការ | ក្រសួង ស្ថាប័នផ្តល់សេវា |
| ៥.២ | រៀបចំក្រមប្រតិបត្តិសម្រាប់ការបណ្តុះបណ្តាលមន្ត្រីផ្តល់សេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | ក្រមប្រតិបត្តិ | រៀបចំ | ដាក់ចេញ | - | - | ឯកសារក្រមប្រតិបត្តិ | លេខាធិការដ្ឋាន |
| ៥.៣ | រៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីផ្តល់សេវាសម្រាប់ធុរកិច្ច | វគ្គ | - | ១ | ១ | ១ | របាយការណ៍ | -លេខាធិការដ្ឋាន (ដឹកនាំ)<br>-គ.រ.ឌ.<br>-ក្រសួង ស្ថាប័នផ្តល់សេវា |

## ឧបសម្ព័ន្ធ ២ ៖ តារាងសូចនាករសមិទ្ធកម្មគន្លឹះ

| ល.រ | សូចនាករសមិទ្ធកម្មគន្លឹះ | ប្រេកង់ | បន្ទាត់មូលដ្ឋាន | ចំណុចដៅ | | | | ក្រសួង ស្ថាប័ន ទទួលបន្ទុក |
|---|---|---|---|---|---|---|---|---|
| | | | | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | |
| ១ | ភាគរយនៃសេវាសម្រាប់ធុរកិច្ចដែលមានអាទិភាពខ្ពស់ត្រូវបានរៀបចំជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច | ប្រចាំឆ្នាំ | ៤% | ១៤% | ២៩% | ៥៤% | ៨០% | -គ.ស.ធ.ឌ. (ដឹកនាំ)<br>-ក្រសួង ស្ថាប័នផ្ដល់សេវា |
| ២ | ភាគរយនៃក្រសួង ស្ថាប័នដែលមានសេវាសម្រាប់ធុរកិច្ចយ៉ាងតិច ១ បានចូលក្នុងប្រព័ន្ធអេកូឡូស៊ីសម្រាប់ធុរកិច្ច | ប្រចាំឆ្នាំ | ៤៨% | ៥២% | ៦០% | ៧០% | ៨០% | -លេខាធិការដ្ឋាន (ដឹកនាំ)<br>-ក្រសួង ស្ថាប័នផ្ដល់សេវា |

## ឧបសម្ព័ន្ធ ៣ ៖ តារាងសេវាមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ន ដែលត្រូវរៀបចំជាសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

### ១. ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | ការផ្តល់សេវាទិដ្ឋាការអេឡិចត្រូនិក (ទេសចរណ៍ T និង ប្រភេទធម្មតា E) | ២០២៨ |

### ២. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | សំណើសុំគម្រោងវិនិយោគថ្មី និង ការងារចុះត្រួតពិនិត្យគម្រោង និង សំណើពង្រីកផលិតកម្ម | ២០២៥ |
| ២ | សំណើសុំនាំចូលដោយរដ្ឋជាអ្នកទទួលបន្ទុកលើពន្ធនាំចូល(លើកទី១ និង បន្តបន្ទាប់) | ២០២៥ |
| ៣ | សំណើសុំវិញ្ញាបនបត្របញ្ជាក់ស្តីពីការបំពេញបាននូវកាតព្វកិច្ចចំពោះរដ្ឋ | ២០២៥ |
| ៤ | សំណើសុំពន្យាសុពលភាពលើលិខិតអនុញ្ញាតនាំចូលដោយរដ្ឋជាអ្នកទទួលបន្ទុកពន្ធនាំចូល | ២០២៦ |
| ៥ | សំណើសុំផ្ទេរភាគហ៊ុន | ២០២៧-២០២៨ |
| ៦ | សំណើសុំប្តូរអ្នកតំណាង | ២០២៧-២០២៨ |
| ៧ | សំណើសុំប្តូរអភិបាល | ២០២៧-២០២៨ |
| ៨ | សំណើសុំប្តូរនាមករណ៍ក្រុមហ៊ុន | ២០២៧-២០២៨ |
| ៩ | សំណើសុំប្តូរទីស្នាក់ការក្រុមហ៊ុន | ២០២៧-២០២៨ |
| ១០ | សំណើសុំបន្ថែមមុខសញ្ញាផលិតកម្ម | ២០២៧-២០២៨ |
| ១១ | សំណើសុំប្តូរមុខសញ្ញាផលិតកម្ម | ២០២៧-២០២៨ |
| ១២ | សំណើសុំផ្ទេរ និង លក់គ្រឿងម៉ាស៊ីន | ២០២៧-២០២៨ |
| ១៣ | សំណើសុំបន្ថែម/បន្ថយដើមទុនចុះបញ្ជី | ២០២៧-២០២៨ |
| ១៤ | ការពិនិត្យ និង អនុម័តផែនការមេនៃបណ្តាកោះ និង ផ្ទេរ | ២០២៧-២០២៨ |

## ៣. ក្រសួងអប់រំ យុវជន និង កីឡា

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | អាជ្ញាបណ្ណសាលាគ្រប់កម្រិត | ២០២៦ |
| ២ | ការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណគ្រប់កម្រិត (សម្រាប់អាជ្ញាបណ្ណចេញមុនឆ្នាំ២០១៧)(កម្មវិធីជាតិ ឬ អន្តរជាតិ) | ២០២៦ |
| ៣ | ប្តូរឈ្មោះគ្រឹះស្ថានសិក្សាគ្រប់កម្រិត ពីមត្តេយ្យ-ទុតិយភូមិ (កម្មវិធីជាតិ ឬ អន្តរជាតិ) | ២០២៧ |
| ៤ | ការប្តូរទីតាំងគ្រឹះស្ថានសិក្សា | ២០២៧ |
| ៥ | ការប្តូរគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា | ២០២៨ |

## ៤. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ក. សេវាថ្នាក់ជាតិ | | |
| ១ | វិញ្ញាបនបត្រលើកដំបូងសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ២០២៥ |
| ២ | បន្តសុពលភាពសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ២០២៥ |
| ៣ | បន្តសុពលភាព និង/ឬ តម្លើងកម្រិតសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ២០២៥ |
| ៤ | បន្តសុពលភាព និង/ឬ បន្ថយកម្រិតសម្រាប់រូបវន្តបុគ្គលសិក្សាគម្រោងប្លង់ | ២០២៥ |
| ៥ | វិញ្ញាបនបត្រលើកដំបូងសម្រាប់សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ | ២០២៥ |
| ៦ | បន្តសុពលភាព សម្រាប់សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ | ២០២៥ |
| ៧ | បន្តសុពលភាព និង/ឬ តម្លើងប្រភេទ សម្រាប់សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ | ២០២៥ |
| ៨ | បន្តសុពលភាព និង/ឬ បន្ថយប្រភេទ សម្រាប់សហគ្រាស ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់ | ២០២៥ |
| ៩ | លិខិតអនុញ្ញាតសាងសង់សំណង់លំនៅឋាន៖ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ | ២០២៥ |
| ១០ | លិខិតអនុញ្ញាតសាងសង់សំណង់ចម្រុះ៖ លំនៅឋាន ការិយាល័យ ពាណិជ្ជកម្ម រោងចក្រ អប់រំ ពេទ្យ ........... | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១១ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងឧស្សាហកម្ម៖ អគារឃ្លាំង រោងចក្រកាត់ដេរគ្រប់ប្រភេទ វារីអគ្គិសនី រោងចក្រអគ្គិសនី រោងចក្រស៊ីម៉ង់ត៍ ចំណតរថភ្លើង អាកាសយានដ្ឋាន និង ប្រភេទសំណង់ឧស្សាហកម្មផ្សេងៗទៀត | ២០២៥ |
| ១២ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងពាណិជ្ជកម្ម៖ ស្ថានីយប្រេងឥន្ធនៈ កន្លែងស្តុកហ្គាស ផ្សារអគារលក់ទំនិញ ភោជនីយដ្ឋាន អគារការិយាល័យ បុរី ផ្ទះស្នាក់នៅរួម ធនាគារ អគារសហកម្មសិទ្ធិ និង ប្រភេទសំណង់ពាណិជ្ជកម្មផ្សេងៗទៀត | ២០២៥ |
| ១៣ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងសេវាកម្ម៖ ផ្ទះជួល ផ្ទះសំណាក់ ផ្ទះស្នាក់នៅគ្រួសារ មូតែល សណ្ឋាគារ គ្រប់ប្រភេទ រីស៊ត កាស៊ីណូ ក្លឹបកម្សាន្ត សួនសត្វ រមណីយដ្ឋាន មណ្ឌលកម្សាន្ត កំពង់ផែ ចំណតរថយន្ត និង ប្រភេទសំណង់ សេវាកម្មផ្សេងៗទៀត | ២០២៥ |
| ១៤ | លិខិតអនុញ្ញាតសាងសង់សំណង់វិនិយោគ៖ តំបន់សេដ្ឋកិច្ចពិសេស តំបន់អភិវឌ្ឍន៍មានលក្ខណៈជាក្រុង ឬ ក្រុងរណប ការអភិវឌ្ឍកោះ អង់តែនទូរស័ព្ទ អង់តែនទូរទស្សន៍-វិទ្យុ ស្ថានីយវិទ្យុ-ទូរទស្សន៍ ស្ថានីយផ្កាយរណប និង ប្រភេទសំណង់វិនិយោគផ្សេងៗទៀត | ២០២៥ |
| ១៥ | សំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ និង សុខាភិបាល៖ កីឡដ្ឋាន អគារកីឡា មហោស្រព រោងកុន សាលពិព័រណ៍ សាលសន្និសីទ រោងល្ខោន រោងសៀក គ្រឹះស្ថានអប់រំ គ្រប់ប្រភេទ មណ្ឌលសុខភាពសម្ភព គ្លីនិក ប្រភេទសំណង់អប់រំ វប្បធម៌ និង សុខាភិបាលផ្សេងទៀត | ២០២៥ |
| ១៦ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងកសិកម្ម៖ កសិដ្ឋានចិញ្ចឹមសត្វ រោងចិញ្ចឹមសត្វ រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងដាក់កសិផល ឃ្លាំងជី អគារបម្រើរចនាសម្ព័ន្ធកសិកម្ម និង ប្រភេទសំណង់កសិកម្មផ្សេងទៀត | ២០២៥ |
| ១៧ | លិខិតអនុញ្ញាតរុះរើ | ២០២៥ |
| ១៨ | លិខិតអនុញ្ញាតជួសជុល | ២០២៥ |
| ១៩ | លិខិតអនុញ្ញាតរុះរើ និង ជួសជុល | ២០២៥ |
| ២០ | លិខិតអនុញ្ញាតរុះរើ ជួសជុល និង សាងសង់ពង្រីកបន្ថែម | ២០២៥ |
| ២១ | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម ឬ បន្ថែមជាន់ | ២០២៥ |
| ២២ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្តូរសោភណភាព ឬ ប្តូរមុខងារប្រើប្រាស់អគារ (ករណីរក្សាក្រឡាផ្ទៃសំណង់សរុបដដែល) | ២០២៥ |
| ២៣ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្តូរសោភណភាព ឬ ប្តូរមុខងារប្រើប្រាស់អគារ (ករណីមានបន្ថែមក្រឡាផ្ទៃសំណង់) | ២០២៥ |
| ២៤ | សេវាឆែកព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក QR Search (ការពិនិត្យព័ត៌មានក្បាលដី ៥,០០០៛, ការឆែកបន្ទុក ៥០,០០០៛, និង ការពិនិត្យទីតាំង និងរូបរាងដី ៤០, ០០០៛)។ | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ២៥ | លិខិតអនុញ្ញាតបើកការដ្ឋាន | ២០២៥ |
| ២៦ | ការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់សម្រាប់ក្រុមហ៊ុន | ២០២៥ |
| ២៧ | ការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់សម្រាប់ក្រុមហ៊ុន | ២០២៥ |
| ២៨ | ការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់សម្រាប់អ្នកវិជ្ជាជីវៈ | ២០២៥ |
| ២៩ | ការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់សម្រាប់អ្នកវិជ្ជាជីវៈ | ២០២៥ |
| **ខ. សេវាថ្នាក់ក្រោមជាតិ** | | |
| ១ | ការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ(ក្នុង ១ក្បាលដី/ប័ណ្ណ) ដីផលិតកម្ម កសិកម្ម នៅរាជធានី ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (បើលើស ១ហិកតា បន្ថែម ៣០,០០០រៀល ក្នុង១ហិកតា) | ២០២៥ |
| ២ | ការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ ដីផលិតកម្ម កសិកម្ម ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) (បើលើស៥ហិកតា បន្ថែម ២០ ០០០ រៀលក្នុង ១ ហិកតា) | ២០២៥ |
| ៣ | ការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ ដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ដីក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) (បើលើស ៥ហិកតា បន្ថែម ១០ ០០០ រៀល ក្នុង ១ ហិកតា) | ២០២៥ |
| ៤ | ការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ ដីលំនៅឋាន ឬ ដីសាងសង់ នៅរាជធានី ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង១ក្បាលដី/ប័ណ្ណ) (បើលើស១ហិកតា បន្ថែម ៦០,០០០ រៀលក្នុង ១ ហិកតា) | ២០២៥ |
| ៥ | ការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) (បើលើស ១ ហិកតាបន្ថែម ៤០ ០០០ រៀលក្នុង ១ ហិកតា) | ២០២៥ |
| ៦ | ការចុះបញ្ជីការផ្ទេរកម្មសិទ្ធិ ឬ ភោគៈ ឬ ការចុះបញ្ជីអំពីការផ្ទេរចំណែកកម្មសិទ្ធិអវិភាគ ឬ ចំណែកភោគៈ ដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ដីក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) (បើលើស ១ ហិកតា បន្ថែម ២០ ០០០ រៀលក្នុង ១ ហិកតា) | ២០២៥ |
| ៧ | ការចុះបញ្ជី និង ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនទូទៅ ឬ ការចុះបញ្ជី និង ចេញវិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ចំនែកឯកជនទូទៅ (ក្នុង ១ ចំណែកឯកជន/ប័ណ្ណ) | ២០២៥ |
| ៨ | ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិលើចំណែកឯកជនទូទៅ | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ៩ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត លើដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្រុងរបស់ខេត្តកណ្ដាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១០ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត លើដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្តក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១១ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្តលើដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ ប័ណ្ណ) | ២០២៥ |
| ១២ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត លើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានីក្រុងរបស់ខេត្តកណ្ដាល ខេត្តព្រះសីហនុ និងខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១៣ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត លើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១៤ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែកបន្ត លើដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១៥ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ដើម្បីធានាបំណុលអណ្តែត លើដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្ដាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាល/ដីប័ណ្ណ) | ២០២៥ |
| ១៦ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ឬការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ដើម្បីធានាបំណុលអណ្តែត លើដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្ដាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១៧ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ដើម្បីធានាបំណុលអណ្តែត លើដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ១៨ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ដើម្បីធានាបំណុលអណ្តែត លើដីលំនៅឋាន ឬ សាងសង់ ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្ដាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១៩ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ដើម្បីធានាបំណុលអណ្តែត លើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២០ | ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែត ឬ ការចុះបញ្ជីអំពីការបង្កើតហ៊ីប៉ូតែករួម ដើម្បីធានាបំណុលអណ្តែត លើដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២១ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីហ៊ីប៉ូតែកលើដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង១ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២២ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីហ៊ីប៉ូតែកលើដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៣ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីហ៊ីប៉ូតែកលើដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៤ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីហ៊ីប៉ូតែកលើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៥ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីហ៊ីប៉ូតែកលើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៦ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីហ៊ីប៉ូតែកលើដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៧ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែតលើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៨ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែតលើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ២៩ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែតលើដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣០ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែតលើដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣១ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក ដើម្បីធានាបំណុលអណ្តែតលើដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ៣២ | ការចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែតលើដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣៣ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកលើដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣៤ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកលើដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣៥ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកលើដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣៦ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកលើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដីប័ណ្ណ) | ២០២៥ |
| ៣៧ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកលើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣៨ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែកលើដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៣៩ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែតលើដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង១ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៤០ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែតលើដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្ត ព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៤១ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែតលើដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៤២ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែត លើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានី ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៤៣ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែត លើដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៤៤ | ការចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ដើម្បីជានាបំណុលអណ្តែត លើដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដី/ប័ណ្ណ) | ២០២៥ |
| ៤៥ | ការបង្រួមក្បាលដី ដីផលិតកម្ម កសិកម្ម ក្នុងរាជធានីភ្នំពេញ ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប តម្លៃក្នុង ១ ក្បាលដីដើម | ២០២៥ |
| ៤៦ | ការបង្រួមក្បាលដី ដីផលិតកម្ម កសិកម្ម ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប តម្លៃក្នុង ១ ក្បាលដីដើម | ២០២៥ |
| ៤៧ | ការបង្រួមក្បាលដី ដីផលិតកម្ម កសិកម្ម នៅជនបទ ឬ ដីក្រៅក្រុង តម្លៃក្នុង ១ ក្បាលដីដើម | ២០២៥ |
| ៤៨ | ការបង្រួមក្បាលដី ដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានីភ្នំពេញ ឬ ក្នុងក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប តម្លៃក្នុង ១ ក្បាលដីដើម | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ៤៩ | ការបង្រួមក្បាលដី ដីលំនៅឋាន ឬ ដីសាងសង់ ក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប តម្លៃក្នុង ១ ក្បាលដីដើម | ២០២៥ |
| ៥០ | ការបង្រួមក្បាលដី ដីលំនៅឋាន ឬ ដីសាងសង់ នៅជនបទ ឬ ដីក្រៅក្រុង តម្លៃក្នុង ១ ក្បាលដីដើម | ២០២៥ |
| ៥១ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ បន្ថែមតម្លៃសេវា (ដូច៥ ២០១៧) ដីផលិតកម្ម កសិកម្ម ក្នុងរាជធានី ក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដីដែលបំបែក) | ២០២៥ |
| ៥២ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ បន្ថែមតម្លៃសេវា (ដូច៥ ២០១៧) ដីផលិតកម្ម កសិកម្ម ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដីដែលបំបែក) | ២០២៥ |
| ៥៣ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ បន្ថែមតម្លៃសេវា (ដូច៥ ២០១៧) ដីផលិតកម្ម កសិកម្ម ដីជនបទ ឬ ដីក្រៅក្រុង (ក្នុង ១ក្បាល ដីដែលបំបែក) | ២០២៥ |
| ៥៤ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ បន្ថែមតម្លៃសេវា (ដូច៨ ២០១៧) ដីលំនៅឋាន ឬ ដីសាងសង់ ក្នុងរាជធានី ក្រុងរបស់ខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដីដែលបំបែក) | ២០២៥ |
| ៥៥ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ បន្ថែមតម្លៃសេវា (ដូច៥ ២០១៧) ដីលំនៅឋាន ឬ ដីសាងសង់ ដីក្នុងក្រុងគ្រប់ខេត្ត ក្រៅពីខេត្តកណ្តាល ខេត្តព្រះសីហនុ និង ខេត្តសៀមរាប (ក្នុង ១ ក្បាលដីដែលបំបែក) | ២០២៥ |
| ៥៦ | ការបំបែកក្បាលដីដោយមិនផ្ទេរសិទ្ធិ បន្ថែមតម្លៃសេវា (ដូច៥ ២០១៧) ដីលំនៅឋាន ឬ ដីសាងសង់ ដីជនបទ ឬ ក្រៅក្រុង (ក្នុង ១ ក្បាលដីដែលបំបែក) | ២០២៥ |
| ៥៧ | លិខិតអនុញ្ញាតសាងសង់សំណង់លំនៅឋាន៖ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ | ២០២៥ |
| ៥៨ | លិខិតអនុញ្ញាតសាងសង់ សំណង់ចម្រុះ៖ លំនៅឋាន ការិយាល័យ ពាណិជ្ជកម្ម រោងចក្រ អប់រំ ពេទ្យ .......... | ២០២៥ |
| ៥៩ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងឧស្សាហកម្ម៖ អគារឃ្លាំង រោងចក្រកាត់ដេរគ្រប់ប្រភេទ វារីអគ្គិសនី រោងចក្រអគ្គិសនី រោងចក្រស៊ីម៉ង់ត៍ ចំណតរថភ្លើង អាកាសយានដ្ឋាន និង ប្រភេទសំណង់ឧស្សាហកម្មផ្សេងៗទៀត | ២០២៥ |
| ៦០ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងពាណិជ្ជកម្ម៖ ស្ថានីយប្រេងឥន្ធនៈ កន្លែងស្តុកហ្គាស ផ្សារអគារលក់ទំនិញ ភោជនីយដ្ឋាន អគារការិយាល័យ ធនាគារ បុរី ផ្ទះស្នាក់នៅរួម អគារសហកម្មសិទ្ធិ និង ប្រភេទសំណង់ពាណិជ្ជកម្មផ្សេងៗទៀត | ២០២៥ |
| ៦១ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងសេវាកម្ម៖ ផ្ទះជួល ផ្ទះសំណាក់ ផ្ទះស្នាក់នៅគ្រួសារ ម៉ូតែល សណ្ឋាគារ គ្រប់ប្រភេទ វីឡា កាស៊ីណូ ក្លឹបកម្សាន្ត សួនសត្វ រមណីយដ្ឋាន មណ្ឌលកម្សាន្ត កំពង់ផែ ចំណតរថយន្ត និង ប្រភេទសំណង់សេវាកម្មផ្សេងៗទៀត | ២០២៥ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ៦២ | លិខិតអនុញ្ញាតសាងសង់សំណង់វិនិយោគៈ តំបន់សេដ្ឋកិច្ចពិសេស តំបន់អភិវឌ្ឍន៍ មានលក្ខណៈជាក្រុង ឬ ក្រុងរណប ការអភិវឌ្ឍកោះ អង់តែនទូរស័ព្ទ អង់តែនទូរទស្សន៍-វិទ្យុ ស្ថានីយវិទ្យុ-ទូរទស្សន៍ ស្ថានីយផ្កាយរណប និង ប្រភេទសំណង់វិនិយោគផ្សេងៗទៀត | ២០២៥ |
| ៦៣ | សំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ និង សុខាភិបាលៈ កីឡដ្ឋាន អគារកីឡា មហោស្រព រោងកុន សាលពិព័រណ៍ សាលសន្និសីទ រោងល្ខោន រោងសៀក គ្រឹះស្ថានអប់រំគ្រប់ប្រភេទ មណ្ឌលសុខភាពសម្ភព គ្លីនិក ប្រភេទសំណង់អប់រំ វប្បធម៌ និង សុខាភិបាលផ្សេងទៀត | ២០២៥ |
| ៦៤ | លិខិតអនុញ្ញាតសាងសង់សំណង់ដែលមានឧបនិស្ស័យខាងកសិកម្មៈ កសិដ្ឋានចិញ្ចឹមសត្វ រោងចិញ្ចឹមសត្វ រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងដាក់កសិផល ឃ្លាំងជី អគារបម្រើរចនាសម្ព័ន្ធកសិកម្ម និង ប្រភេទសំណង់កសិកម្មផ្សេងទៀត | ២០២៥ |
| ៦៥ | លិខិតអនុញ្ញាតរុះរើ | ២០២៥ |
| ៦៦ | លិខិតអនុញ្ញាតជួសជុល | ២០២៥ |
| ៦៧ | លិខិតអនុញ្ញាតរុះរើ និង ជួសជុល | ២០២៥ |

## ៥. ក្រសួងមហាផ្ទៃ

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | ទិដ្ឋាការតាមប្រព័ន្ធអេឡិចត្រូនិក (E-Arrival) | ២០២៥-២០២៨ |
| ២ | ផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបុគ្គល | ២០២៥-២០២៨ |
| ៣ | បញ្ជាក់អត្តសញ្ញាណបុគ្គល និង បញ្ជាក់ភាពត្រឹមត្រូវនៃទិន្នន័យអត្តសញ្ញាណបុគ្គល | ២០២៥-២០២៨ |
| ៤ | លិខិតឆ្លងដែន | ២០២៥-២០២៨ |

## ៦. ក្រសួងយុត្តិធម៌

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | ព្រឹត្តបត្រថ្កោលទោសលេខ ៣ | ២០២៨ |

## ៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | លិខិតអនុញ្ញាតបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និង/ឬ បង្កាត់ពូជសត្វ | ២០២៥ |
| ២ | វិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្ម | ២០២៥ |
| ៣ | វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំង សន្និធិជីកសិកម្ម | ២០២៥ |
| ៤ | លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយជីកសិកម្ម | ២០២៥ |
| ៥ | វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម | ២០២៥ |
| ៦ | វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំង សន្និធិថ្នាំកសិកម្ម | ២០២៥ |
| ៧ | លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម | ២០២៦ |
| ៨ | វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពូជដំណាំ | ២០២៦ |
| ៩ | វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ | ២០២៦ |
| ១០ | លិខិតអនុញ្ញាតធ្វើអាជីវកម្ម ផលិត កែច្នៃពូជដំណាំ | ២០២៦ |
| ១១ | វិញ្ញាបនបត្រចុះបញ្ជីចំណីសត្វ ឬ បសុឱសថ | ២០២៦ |
| ១២ | វិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិចំណីសត្វ ឬ បសុឱសថ | ២០២៦ |
| ១៣ | លិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយចំណីសត្វ ឬ បសុឱសថ | ២០២៦ |
| ១៤ | លិខិតអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន | ២០២៦ |
| ១៥ | លិខិតអនុញ្ញាតធ្វើអាជីវកម្មពិឃាតសត្វ | ២០២៦ |
| ១៦ | លិខិតអនុញ្ញាតប្រមូលទិញសត្វ និង ផលិតផលមានដើមកំណើតពីសត្វ | ២០២៦ |
| ១៧ | លិខិតអនុញ្ញាតបង្កើតទីតាំងទិញ លក់ សន្និធិ ឬ កន្លែងកែច្នៃផលផលិតផលជលផល | ២០២៦ |
| ១៨ | លិខិតអនុញ្ញាតធ្វើវារីវប្បកម្ម | ២០២៧ |
| ១៩ | លិខិតអនុញ្ញាតចិញ្ចឹមក្រពើ | ២០២៧ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ២០ | លិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារ | ២០២៧ |
| ២១ | លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ | ២០២៧ |
| ២២ | លិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃ | ២០២៧ |
| ២៣ | ការបង្កើត/ពន្យារសុពលភាពរោងលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ | ២០២៧ |
| ២៤ | ការបង្កើត/ពន្យារសុពលភាពរោងម៉ាស៊ីន និង រោងសិប្បកម្មអារកែច្នៃផល អនុផលព្រៃឈើ | ២០២៧ |
| ២៥ | ប័ណ្ណប្រើប្រាស់យានយន្ត និង រណារយន្តកាត់-អារឈើ | ២០២៧ |
| ២៦ | សេវាសម្រាប់ចុះបញ្ជិកា ឬ ចុះបញ្ជិកាជាថ្មី រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋាន | ២០២៧ |
| ២៧ | ទទួលស្គាល់ជាផ្លូវការ ឬទទួលស្គាល់ជាផ្លូវការជាថ្មី មន្ទីពិសោធន៍មូលដ្ឋាន | ២០២៧ |
| ២៨ | សេវាសម្រាប់ធ្វើតេស្ត និង ការចេញវិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជាក្នុងមួយកែស ប៉ាឡែត | ២០២៨ |
| ២៩ | លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬ វេចខ្ចប់ជាថ្មីជីកសិកម្ម | ២០២៨ |
| ៣០ | លិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬ វេចខ្ចប់ជាថ្មីថ្នាំកសិកម្ម | ២០២៨ |
| ៣១ | លិខិតអនុញ្ញាតផលិត លាយផ្សំ ឬ វេចខ្ចប់ជាថ្មីចំណីសត្វ ឬ បសុឱសថ | ២០២៨ |
| ៣២ | លិខិតអនុញ្ញាតបង្កើតកន្លែងលក់ដុំលក់រាយចំណីសត្វ ឬ បសុឱសថ | ២០២៨ |
| ៣៣ | លិខិតអនុញ្ញាតបង្កើតឃ្លាំងសន្និធិស្បែកគោ ក្របី | ២០២៨ |
| ៣៤ | លិខិតអនុញ្ញាតបង្កើតកន្លែងផលិត កែច្នៃសាច់ និង ផលិតផលសត្វបឋម | ២០២៨ |
| ៣៥ | លិខិតអនុញ្ញាតបង្កើតកន្លែងសន្និធិសាច់ និង/ឬ ផលិតផលសត្វ | ២០២៨ |
| ៣៦ | លិខិតអនុញ្ញាតបង្កើតកន្លែងពិនិត្យព្យាបាលសត្វ (មន្ទីរពេទ្យសត្វ) | ២០២៨ |
| ៣៧ | លិខិតអនុញ្ញាតបង្កើតស្ថានីយចត្តាឡីស័កសត្វ និង ផលិតផលសត្វ | ២០២៨ |
| ៣៨ | លិខិតទទួលស្គាល់សមត្ថភាពវិជ្ជាជីវៈ បុគ្គលិកបច្ចេកទេសប្រចាំគ្រឹះស្ថានសត្វផលិតផលសត្វ ចំណីសត្វ បសុឱសថ (ជនជាតិខ្មែរ និង បរទេស) | ២០២៨ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ៣៩ | លិខិតទទួលស្គាល់៖ ១.គ្រឹះស្ថានស្រាវជ្រាវឯកជនពាក់ព័ន្ធសត្វ ផលិតផលសត្វ ចំណីសត្វ និងបសុឱសថ ២.អ្នកស្រាវជ្រាវសាកល្បងលើសត្វ ផលិតផលសត្វ ចំណីសត្វ និងបសុឱសថ (ជនជាតិខ្មែរ និង ជនបរទេស) | ២០២៨ |
| ៤០ | លិខិតទទួលស្គាល់កិច្ចប្រតិបត្តិរបស់មន្ទីរពិសោធន៍សម្រាប់៖ ១.វិភាគជំងឺសត្វ និង ផលិតផលសត្វ និង ២. វិភាគចំណីសត្វ និងបសុឱសថ | ២០២៨ |
| ៤១ | វិញ្ញាបនបត្របញ្ជាក់ការអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) | ២០២៨ |

## ៨. ក្រសួងពាណិជ្ជកម្ម

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ | ២០២៨ |
| ២ | អាជ្ញាបណ្ណនាំចេញ | ២០២៨ |
| ៣ | ការពន្យារសុពលភាពអាជ្ញាបណ្ណនាំចេញ | ២០២៨ |
| ៤ | អាជ្ញាបណ្ណនាំចូល | ២០២៨ |
| ៥ | ការពន្យារសុពលភាពអាជ្ញាបណ្ណនាំចូល | ២០២៨ |
| ៦ | លិខិតបញ្ជាក់ការនាំចូលត្បូងថ្មមិនទាន់កែច្នៃក្រោមគឹមប័រលីប្រូសេស(Kimberly Process) | ២០២៨ |
| ៧ | វិញ្ញាបនបត្រនាំចេញត្បូងថ្មមិនទាន់កែច្នៃក្រោមគឹមប័រលីប្រូសេស(Kimberly Process) | ២០២៨ |
| ៨ | ចុះបញ្ជិការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ឬ សម្រាប់ស្វ័យបញ្ជាក់ដើមកំណើតទំនិញ | ២០២៨ |
| ៩ | ការស្នើសុំលិខិតអនុញ្ញាតតាមប្រព័ន្ធអេឡិចត្រូនិក | ២០២៨ |
| ១០ | ការស្នើសុំលិខិតអនុញ្ញាតតាមប្រព័ន្ធអេឡិចត្រូនិក (បន្តសុពលភាព) | ២០២៨ |
| ១១ | ការស្នើសុំលិខិតអនុញ្ញាតតាមប្រព័ន្ធអេឡិចត្រូនិក (កែប្រែព័ត៌មាន) | ២០២៨ |
| ១២ | ការស្នើសុំលិខិតអនុញ្ញាតតាមប្រព័ន្ធអេឡិចត្រូនិក (ផ្អាក ឬ បិទ) | ២០២៨ |
| ១៣ | ការស្នើសុំអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ២០២៨ |
| ១៤ | ការស្នើសុំអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (បន្តសុពលភាព) | ២០២៨ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១៥ | ការស្នើសុំអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (កែប្រែព័ត៌មាន) | ២០២៨ |
| ១៦ | ការស្នើសុំអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ផ្អាក ឬ បិទ) | ២០២៨ |
| ១៧ | ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក | ២០២៨ |
| ១៨ | ការជូនដំណឹងជាមុនអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច | ២០២៨ |
| ១៩ | ការចេញវិញ្ញាបនបត្រជាមុននៃការរួមបញ្ចូលគ្នានៃធុរកិច្ច | ២០២៨ |
| ២០ | ការជូនដំណឹងជាក្រោយអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច | ២០២៨ |
| ២១ | ការចុះបញ្ជិការរួមបញ្ចូលគ្នានៃធុរកិច្ច | ២០២៨ |

## ៩. ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ១ | ការផ្តល់វិញ្ញាបនបត្រថ្មី និងបន្ត (ដើមទុនលើសពី ១ 000 000ដុល្លារ) | ២០២៦ |
| ២ | លិខិតអនុញ្ញាតពង្រីកផលិតកម្ម ឬ ប្តូរទីតាំង ឬ ប្តូរម្ចាស់ ឬ ប្តូរឈ្មោះ ឬ ទុតិយតាសិប្បកម្ម ដែលមានហានិភ័យ (ដើមទុនតិចជាង ឬ ស្មើ ៥0 000 ដុល្លារ) | ២០២៦ |
| ៣ | លិខិតអនុញ្ញាតពង្រីកផលិតកម្ម ឬ ប្តូរទីតាំង ឬ ប្តូរម្ចាស់ ឬ ប្តូរឈ្មោះ ឬទុតិយតាសហគ្រាសធុនតូច (ដើមទុនលើសពី ៥0 000ដុល្លារ ដល់ ៥00 000 ដុល្លារ) | ២០២៦ |
| ៤ | លិខិតអនុញ្ញាតពង្រីកផលិតកម្ម ឬ ប្តូរទីតាំង ឬ ប្តូរម្ចាស់ ឬ ប្តូរឈ្មោះ ឬ ទុតិយតាសហគ្រាសធុនមធ្យម (ដើមទុនលើសពី ៥00 000 ដុល្លារ ដល់ ១ 000 000 ដុល្លារ) | ២០២៦ |
| ៥ | ការផ្តល់អាជ្ញាបណ្ណចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា (ចបផ, សុវត្ថិភាព) សម្រាប់ផលិតផលអគ្គិសនី ឬ អេឡិចត្រូនិក ឬ ផលិតផលកៅស៊ូ ឬ គ្រឿងសង្ហារឹម ឬ សម្ភារសំណង់ | ២០២៦ |
| ៦ | ការផ្តល់អាជ្ញាបណ្ណចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដារកម្ពុជា (ចបផ, សុវត្ថិភាព) សម្រាប់ផលិតផលម្ហូបអាហារ ឬ សារជាតុនិងផលិតផលគីមីជាប់បញ្ញត្តិ ឬ ផលិតផលផ្សេងៗ | ២០២៦ |
| ៧ | ការលក់ស្តង់ដារកម្ពុជា - ចាប់ពី ១ ទំព័រ ដល់ ២០ ទំព័រ | ២០២៦ |
| ៨ | ការលក់ស្តង់ដារកម្ពុជា - ចាប់ពី ២១ ទំព័រ ដល់ ៥0ទំព័រ | ២០២៦ |

| ល.រ. | ឈ្មោះសេវាអាទិភាព | ឆ្នាំអនុវត្ត |
|---|---|---|
| ៩ | ការលក់ស្តង់ដារកម្ពុជា - ចាប់ពី ៥១ ទំព័រ | ២០២៦ |
| ១០ | វិញ្ញាបនបត្របញ្ជាក់ភាពអនុលោមផលិតផល | ២០២៦ |
| ១១ | អាជ្ញាបណ្ណប្រើសញ្ញាស្តង់ដារផលិតផល | ២០២៦ |
| ១២ | ចុះត្រួតពិនិត្យ និង វាយតម្លៃប្រព័ន្ធផលិតកម្មអនុលោមស្តង់ដារផលិតផល ( សម្រាប់ ១នាក់/១ថ្ងៃ ) | ២០២៦ |
| ១៣ | ការផ្តល់លិខិតបញ្ជាក់ការផ្លាស់ប្តូរផ្នែកណាមួយនៃផលិតផលយានយន្ត ឬ ផលិតផលអគ្គិសនី ឬ អេឡិចត្រូនិក | ២០២៦ |
| ១៤ | ចុះបញ្ជី អង្គភាពវាយតម្លៃភាពអនុលោម ឬវិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់ ឬវិញ្ញាបនបត្រវាយតម្លៃភាពអនុលោម ឬរបាយការណ៍អង្គភាពអធិការកិច្ច តាមស្តង់ដារ ISO/IEC 17020 | ២០២៦ |
| ១៥ | ផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់លើកដំបូង ដល់មន្ទីរពិសោធន៍ ធ្វើតេស្ត ឬព្យាសកម្ម ឬ PTP ឬ RMP | ២០២៦ |
| ១៦ | ផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់បន្តសុពលភាព ដល់មន្ទីរពិសោធន៍ធ្វើតេស្ត ឬព្យាសកម្ម ឬ PTP ឬ RMP | ២០២៦ |
| ១៧ | ផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់លើកដំបូង ដល់អង្គភាពអធិការកិច្ច តាមស្តង់ដា ISO/IEC 17020 | ២០២៦ |
| ១៨ | ផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់បន្តសុពលភាព ដល់អង្គភាពអធិការកិច្ច តាមស្តង់ដា ISO/IEC 17020 | ២០២៦ |
| ១៩ | ចុះបញ្ជីវាយតម្លៃទទួលស្គាល់លើកដំបូង ដល់មន្ទីរពិសោធន៍ធ្វើតេស្ត ឬ ព្យាសកម្ម ឬ PTP ឬ RMP | ២០២៦ |
| ២០ | ចុះបញ្ជីវាយតម្លៃទទួលស្គាល់បន្តសុពលភាព ដល់មន្ទីរពិសោធន៍ធ្វើតេស្ត ឬ ព្យាសកម្ម ឬ PTP ឬ RMP | ២០២៦ |
| ២១ | ចុះបញ្ជីវាយតម្លៃទទួលស្គាល់លើកដំបូងដល់អង្គភាពអធិការកិច្ច តាមស្តង់ដារ ISO/IEC 17020 | ២០២៦ |
| ២២ | ចុះបញ្ជីវាយតម្លៃទទួលស្គាល់បន្តសុពលភាពដល់អង្គភាពអធិការកិច្ច តាមស្តង់ដារ ISO/IEC 17020 | ២០២៦ |
| ២៣ | ផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់លើកដំបូង ដល់អង្គភាពចេញវិញ្ញាបនបត្រវាយតម្លៃភាពអនុលោមស្តង់ដា | ២០២៦ |
| ២៤ | ផ្តល់វិញ្ញាបនបត្រវាយតម្លៃទទួលស្គាល់បន្តសុពលភាព ដល់អង្គភាពចេញវិញ្ញាបនបត្រវាយតម្លៃភាពអនុលោមស្តង់ដា | ២០២៦ |
